# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

លេខ: ៥០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ១០ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១** ._

អនុក្រឹត្យនេះមានគោលបំណងរៀបចំបន្ថែមរបបសន្តិសុខសង្គមប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព។

**មាត្រា២** ._

អនុក្រឹត្យនេះមានគោលដៅដើម្បីកំណត់នូវ៖

- កម្រិតនៃរបបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព
- ការបន្ថែមរបបសន្តិសុខសង្គមប្រចាំខែលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព ផ្អែកលើកម្រិតនីមួយៗនៃរបបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្ន។

**មាត្រា៣** ._

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ៖

- និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល
- និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន
- របបសន្តិសុខសង្គមប្រចាំខែលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព

មន្ត្រីរាជការដែលទទួលបានការដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានអនុលោមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវដាក់ឱ្យចូលនិវត្តន៍ចាប់ពីខែមករា ឆ្នាំ២០១៦ មិនត្រូវទទួលបានការបន្ថែមរបបសន្តិសុខសង្គមដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះឡើយ។

**មាត្រា៤** ._

ត្រូវបានបន្ថែមរបបសន្តិសុខសង្គមប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជនដូចខាងក្រោម៖

កម្រិត១ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៣០០ ០០០(បីសែន)រៀលដល់ត្រឹម ៣៣០ ០០០ (បីសែនបីម៉ឺន)រៀល ត្រូវបន្ថែមឱ្យដល់ ៣៦០ ០០០(បីសែនប្រាំមួយម៉ឺន)រៀលក្នុង១(មួយ)ខែ

កម្រិត២ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៣៣០ ០០១(បីសែនបីម៉ឺនមួយ)រៀលដល់ត្រឹម៣៩៥ ០០០(បីសែនប្រាំបួនម៉ឺនប្រាំពាន់)រៀល ត្រូវផ្តល់ជូនបន្ថែមចំនួន៣០ ០០០(បីម៉ឺន)រៀលក្នុង១(មួយ)ខែ

កម្រិត៣ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៣៩៥ ០០១(បីសែនប្រាំបួនម៉ឺនប្រាំពាន់មួយ)រៀល ដល់ត្រឹម ៤០០ ០០០(បួនសែន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៤២៥ ០០០(បួនសែនពីរម៉ឺនប្រាំពាន់)រៀលក្នុង១(មួយ)ខែ

កម្រិត៤ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៤០០ ០០១(បួនសែនមួយ)រៀល ដល់ត្រឹម ៤៩៥ ០០០(បួនសែនប្រាំបួនម៉ឺនប្រាំពាន់)រៀល ត្រូវផ្តល់ជូនបន្ថែមចំនួន២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀលក្នុង១(មួយ)ខែ

កម្រិត៥ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៤៥៥ ០០១(បួនសែនហាសិបប្រាំពាន់មួយ)រៀល ដល់ត្រឹម ៥០០ ០០០(ប្រាំសែន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៥២០ ០០០(ប្រាំសែនពីរម៉ឺន)រៀលក្នុង១(មួយ)ខែ

កម្រិត៦ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៥០០ ០០១(ប្រាំសែនមួយ)រៀល ឡើងទៅត្រូវផ្តល់ជូនបន្ថែមចំនួន២០ ០០០(ពីរម៉ឺន)រៀលក្នុង១(មួយ)ខែ។

អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជនដែលបានទទួលការបន្ថែមរបបសន្តិសុខសង្គមប្រចាំខែក្នុងកម្រិតណាមួយខាងលើរួចមកហើយ មិនអាចទទួលបានកម្រិតផ្សេងទៀតឡើយ។

**មាត្រា៥.-**

របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជនប្រចាំខែដែលបានកំណត់ក្នុងមាត្រា៤ខាងលើ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ។

ការកែប្រែរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ត្រូវធ្វើឡើងដោយអនុក្រឹត្យបន្ទាប់ពីការពិគ្រោះយោបល់រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| --- | --- | --- |
| **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **ក្រសួងមុខងារសាធារណៈ** |
| **អូន ព័ន្ធមុនីរ័ត្ន** | **វង សូត** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ